ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០២៣/២០ - បូវយើរ ហ្គាមេន

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **អាំង អេងថុង**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត**

អាសយដ្ឋាន ៖ ភូមិពងទឹក ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០១៧ ៦៦៦ ៨២១ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | | |
|---|---|---|
| ១- | លោក សៀង ដ្បោ | អនុប្រធានផ្នែកធនធានមនុស្ស |
| ២- | លោក សី សម្ផស្ស | ផ្នែកធនធានមនុស្ស |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត**

អាសយដ្ឋាន ៖ ភូមិពងទឹក ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០១២ ៦៦ ៧០ ៣៨/០១២ ៥៧ ៦៤ ៩៥ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក សល់ គីមសាន | ប្រធានសហព័ន្ធ[illegible] |
| ២- លោក សុខ ចន្ធី | ប្រធានសហជីពមូលដ្ឋាន |
| ៣- លោក ឌុក សារិន | ហិរញ្ញិកសហជីពមូលដ្ឋាន |
| ៤- លោក ឈន វណ្ណាត | លេខាសហជីពមូលដ្ឋាន |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- ភាគីកម្មករស្នើសុំឱ្យក្រុមហ៊ុនផ្ដល់ប្រាក់ចំនួន ១០$ (ដុល្លារអាមេរិក) ដូចមុន សម្រាប់ចងដៃកម្មករកម្មការិនីដែលសុំច្បាប់ពិសេស រៀបអាពាហ៍ពិពាហ៍។ ភាគីក្រុមហ៊ុនមិនឯកភាព ដោយសារតែកិច្ចព្រមព្រៀងបានផុតកំណត់ និងការប្រែប្រួលស្ថានភាពរបស់ក្រុមហ៊ុន។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលអំណាចក្នុងការចេញសេចក្ដីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្ដីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ១៨១ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្ដីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្ដីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ ២៧៥/២០ ក.ប/កណ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃព្រហស្បតិ៍ ៩រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តកណ្ដាល បានទទួលលិខិតស្នើសុំឱ្យជួយដោះស្រាយវិវាទការងាររួមរបស់សហជីពកម្ពុជាឯកភាព។ បន្ទាប់ពីទទួលបានពាក្យបណ្ដឹងនេះមក មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តកណ្ដាល បានអញ្ជើញគូភាគីទាំងពីរមកសាកសួរព័ត៌មាន។ រហូតដល់ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តកណ្ដាល ក៏បានអញ្ជើញគូភាគីទាំងពីរមកចូលរួមដោះស្រាយវិវាទការងាររួម ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ៦ចំណុច លើការទាមទារចំនួន ៧ចំណុច។ ចំណុចមិនសះជាចំនួន ១ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ ២៧៥/២០ ក.ប/កណ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ១ចំណុចនេះ នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ៨ និង ៣០ នាទីព្រឹក។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វះរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ១ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទដែលនៅសល់ចំនួន ១ចំណុចនេះ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០២០ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន បូរយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូនលោក សៀង វង្ឋា និង សី សម្ផស្ស ជាតំណាងក្រុមហ៊ុន ដែលមានសិទ្ធិ និងអំណាចពេញលេញ ក្នុងការដោះស្រាយរាល់បញ្ហាវិវាទការងារ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០។

២- លក្ខន្តិកៈក្រុមហ៊ុន បូរយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត បានតម្កល់ទុកលេខ ២០១៤/២០១២ ពណ.ចបព ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន បូរយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ចុះបញ្ជិកា លេខ ១០៦៧/១៨ ក.ប.វ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨ ដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល។

៤- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន បូរយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ MOC-៩៣៣៩១៩៩ ពណ.ចបព ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២។

៥- ប័ណ្ណពន្ធប៉ាតង់ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ PTL-២០១៨០៣៨៣៧១ អពជ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨។

៦- លិខិតចុះថ្ងៃទី៣១ ខែមេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ស្តីពីសំណើសុំផ្តល់របាយការណ៍ និងបន្តសុពលភាពរបស់ក្រុមហ៊ុនមួយឆ្នាំទៀត តាមប្រកាសលេខ ២៣២ ព.ណ.បអព ប្រក ចុះថ្ងៃ ទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងពាណិជ្ជកម្ម។

៧- កិច្ចព្រមព្រៀងការងាររួម រវាងរោងចក្រ បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត និងសហជីពដើម្បីកម្មករ និងនិយោជិតកម្ពុជា បានចុះបញ្ជិកាលេខ ៣៦៧/១៤ ក.ប.វ ចុះថ្ងៃ ទី២៤ ខែមីនា ឆ្នាំ២០១៤ ដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល។

៨- កិច្ចព្រមព្រៀងការងាររួមថ្មី ស្តីពីការធ្វើវិសោធនកម្មលើប្រការ ១៥ និងប្រការ១៦ ។

៩- សេចក្តីបញ្ជាក់ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥។

១០- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០។

១១- លិខិតចុះថ្ងៃសុក្រ ១១កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ របស់តំណាងនាយកក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសារណាសង្ខេបស្តីពីសំណុំរឿងលេខ ០២៣/២០។

១២- បញ្ជីរាយនាមឈ្មោះសហជីពកម្ពុជាឯករាជ្យ អំពីប្រាក់កាត់ភាគទានសហជីព សំរាប់ខែកញ្ញា ឆ្នាំ២០១៩។

១៣- ឯកសារជាភាសាបរទេស។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- វិញ្ញាបនបត្រចុះបញ្ជីកាអង្គការវិជ្ជាជីវៈសហជីពកម្ពុជាឯករាជ្យ នៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ ០៨០/១៧ កប/កណ ចុះថ្ងៃអង្គារ ៩រោច ខែមិគសិរ ឆ្នាំរកា ពស ២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧។

២- លិខិតលេខ ០៨០/១៧ ក.ប/កណ ចុះថ្ងៃថ្ងៃអង្គារ ៩រោច ខែមិគសិរ ឆ្នាំរកា ពស ២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថាសហជីពកម្ពុជាឯករាជ្យ នៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ជាអង្គការវិជ្ជាជីវៈមួយបានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ ។

៣- លិខិតលេខ ១៨៧/១៩ កប/កណ ចុះថ្ងៃសុក្រ ២រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ជម្រាបមក លោកប្រធានសហជីពកម្ពុជាឯករាជ្យ នៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី។

៤- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ប៊ូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០។

៥- លក្ខន្តិកៈនៃសហជីពកម្ពុជាឯករាជ្យ នៃក្រុមហ៊ុន ប៊ូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី បានចុះបញ្ជិកាលេខ ១០៨១៧០០៨១ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល។

៦- កិច្ចព្រមព្រៀងការងាររួម រវាងរោងចក្រ ប៊ូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត និងសហជីពដើម្បីកម្មករ និងនិយោជិតកម្ពុជា បានចុះបញ្ជិកាលេខ ៣៦៧/១៤ ក.ប.រ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ ដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល។

៧- កិច្ចព្រមព្រៀងធ្វើនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤ តំណាងក្រុមហ៊ុន ប៊ូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត និងតំណាងកម្មករ និងតំណាងសហជីព ប្រចាំក្រុមហ៊ុន ប៊ូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ប៊ូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ ២៧៥/២០ ក.ប/កណ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ប៊ូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ប៊ូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ ០០៥/២០ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៤១ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៤២ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០។

## អង្គហេតុ

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ប៊ូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត គឺជាក្រុមហ៊ុនដែលមានសកម្មភាព ផលិតសម្លៀកបំពាក់ និងផលិតផលនាំចេញ ទទួលបានវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជី ពាណិជ្ជកម្ម លេខ ០០០០៤០១៦ ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២។ ក្រុមហ៊ុននេះមាន[illegible]

និយោជិតសរុបចំនួន ៤៣៨៥នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ប៊ូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីតធីត)*។

- យោងតាមពាក្យបណ្តឹងរបស់កម្មករនិយោជិតដែលគាំទ្រសហជីពកម្ពុជាឯករាជ្យ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ មានឈ្មោះ និងស្នាមមេដៃរបស់កម្មករនិយោជិតដែលជាដើមបណ្តឹងចំនួន ១៣នាក់ និងកម្មករនិយោជិតដែលជាតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទរួមបានចូលរួម នៅសវនាការចំនួន ៣នាក់។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកផ្តល់ប្រាក់ចំនួន ១០ដុល្លារអាមេរិក សម្រាប់ចងដៃកម្មករកម្មការិនីដែលសុំច្បាប់ពិសេស រៀបអាពាហ៍ពិពាហ៍ ដូចពីមុន**

- ភាគីទាំងពីរទទួលស្គាល់ថា ៖
    - នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ ភាគីនិយោជក និងសហជីពដើម្បីកម្មករ និងនិយោជិតកម្ពុជា បានចុះកិច្ចព្រមព្រៀងការងាររួមលើកទី១ ដោយនិយោជកផ្តល់ប្រាក់កាដូរៀបអាពាហ៍ពិពាហ៍ចំនួន ១០ដុល្លារអាមេរិក ជូនកម្មករនិយោជិតដែលសុំច្បាប់ពិសេស រៀបអាពាហ៍ពិពាហ៍។ កិច្ចព្រមព្រៀងការងាររួមលើកទី១នេះ មានរយៈពេល ២ឆ្នាំ។ ហេតុនេះ កិច្ចព្រមព្រៀងការងាររួមលើកទី១នេះ ត្រូវផុតសុពលភាពនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦។
    - ចាប់ពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦ ដល់ចុងឆ្នាំ២០១៨ និយោជកបន្តផ្តល់ប្រាក់កាដូរៀបអាពាហ៍ពិពាហ៍ចំនួន ១០ដុល្លារអាមេរិក ជូនកម្មករនិយោជិត។
    - ចាប់ពីឆ្នាំ២០១៩ ដល់បច្ចុប្បន្ន និយោជកបញ្ឈប់ការផ្តល់ប្រាក់កាដូរៀបអាពាហ៍ពិពាហ៍ចំនួន ១០ដុល្លារអាមេរិក ជូនកម្មករនិយោជិត។
    - បច្ចុប្បន្ននេះ នៅក្នុងក្រុមហ៊ុនមិនទាន់មានសហជីពណាមួយទទួលបានភាពជាតំណាងបំផុតនៅឡើយទេ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
    - ទោះបីជាកិច្ចព្រមព្រៀងការងាររួមលើកទី១ បានផុតនៅឆ្នាំ២០១៦ ពិតមែន ក៏ប៉ុន្តែ និយោជកនៅតែបន្តផ្តល់ប្រាក់កាដូរៀបអាពាហ៍ពិពាហ៍ចំនួន ១០ដុល្លារអាមេរិក ជូនកម្មករនិយោជិតដែលសុំច្បាប់ឈប់ពិសេស រៀបអាពាហ៍ពិពាហ៍ រហូតដល់ឆ្នាំ២០១៨ ហេតុនេះ និយោជកគួរតែបន្តផ្តល់ជូនកម្មករនិយោជិតទៀត។
    - ម្យ៉ាងទៀត និយោជកបញ្ឈប់ការផ្តល់ប្រាក់កាដូរៀបអាពាហ៍ពិពាហ៍នេះ ដោយមិនបានជូនដំណឹងដល់កម្មករនិយោជិតនោះទេ។
- ភាគីកម្មករនិយោជិតបានអះអាងថា ចាប់ពីឆ្នាំ២០១៩ រហូតដល់ថ្ងៃសវនាការ មិនមានកម្មករនិយោជិតណាម្នាក់នៅក្នុងសហជីពកម្ពុជាឯករាជ្យ បានរៀបអាពាហ៍ពិពាហ៍នោះទេ។
- នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានស្នើសុំក្រុមអាជ្ញាកណ្តាល ដើម្បីដាក់ឯកសារបញ្ជាក់នូវចំនួនជាក់លាក់នៃកម្មករនិយោជិតដែលបានរៀបអាពាហ៍ពិពាហ៍ ហើយមិនបានទទួលប្រាក់កាដូរៀបអាពាហ៍ពិពាហ៍។
- ភាគីនិយោជករក្សាគោលជំហរ មិនផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖

- និយោជកផ្តល់ប្រាក់កាដូរៀបអាពាហ៍ពិពាហ៍ចំនួន ១០ដុល្លារអាមេរិក ជូនកម្មករនិយោជិត ដែលរៀបអាពាហ៍ពិពាហ៍ ដោយផ្អែកតាមកិច្ចព្រមព្រៀងការងាររួមលើកទី១ រវាងនិយោជក និងសហជីពដើម្បីកម្មករ និងនិយោជិតកម្ពុជា ដែលកិច្ចព្រមព្រៀងនេះបានផុតសុពលភាពក្នុងឆ្នាំ២០១៦ ហើយ។
- នៅឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨ មានការផ្លាស់ប្តូរថ្នាក់ដឹកនាំក្រុមហ៊ុន និងមានការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងមួយចំនួន ហើយនិយោជកមិនបានមើលពីសុពលភាពនៃកិច្ចព្រមព្រៀងការងាររួមនោះទេ។ ហេតុនេះ ទើបនិយោជកផ្តល់ប្រាក់កាដូរៀបអាពាហ៍ពិពាហ៍ចំនួន ១០ ដុល្លារអាមេរិក ជូនកម្មករនិយោជិត តាមការអនុវត្តកន្លងមក។
- នៅចុងឆ្នាំ២០១៨ ក្រុមហ៊ុនមានការផ្លាស់ប្តូរថ្នាក់ដឹកនាំថ្មីម្តងទៀត ដោយថ្នាក់ដឹកនាំថ្មីបានធ្វើការត្រួតពិនិត្យពីបញ្ហាសង្វាក់ផលិតកម្មរបស់ក្រុមហ៊ុន ត្រួតពិនិត្យរាល់ការចំណាយទាំងអស់ និងត្រួតពិនិត្យពីភាពស្របច្បាប់នៃការផ្តល់អត្ថប្រយោជន៍ជូនកម្មករនិយោជិត។ ក្រោយមកថ្នាក់ដឹកនាំបានរកឃើញថា មិនមានឯកសារណាមួយដែលតម្រូវឱ្យនិយោជកផ្តល់ប្រាក់កាដូរៀបអាពាហ៍ពិពាហ៍ចំនួន ១០ដុល្លារអាមេរិក ជូនកម្មករនិយោជិតនោះទេ។ ហេតុនេះ និយោជកសម្រេចមិនផ្តល់ប្រាក់កាដូរៀបអាពាហ៍ពិពាហ៍ជូនកម្មករនិយោជិតទៀតទេ ដោយនិយោជករង់ចាំឱ្យមានការចរចាកិច្ចព្រមព្រៀងជាថ្មី ជាមួយសហជីពដែលមានភាពជាតំណាងបំផុត។
- ម្យ៉ាងទៀត និយោជកយល់ឃើញថា ការផ្តល់ប្រាក់កាដូរៀបអាពាហ៍ពិពាហ៍នេះ គឺជាអត្ថប្រយោជន៍ដែលប្រសើរជាងច្បាប់ ហេតុនេះ មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលអាចចរចាបាន។ ដោយឡែក នៅក្នុងក្រុមហ៊ុនមិនទាន់មានសហជីពដែលមានភាពជាតំណាងបំផុតថ្មីទៀតនោះទេ។
- លើសពីនេះទៀត នៅក្នុងខែកក្កដា ឆ្នាំ២០១៩ នៅក្នុងក្រុមហ៊ុនមានបញ្ហាកូដកម្មទ្រង់ទ្រាយធំ ជាហេតុបណ្តាលឱ្យការមានការពន្យារពេលនៃការបញ្ជាទិញ។ ជាមួយគ្នានេះដែរ មានកម្មករនិយោជិតរៀបអាពាហ៍ពិពាហ៍ចន្លោះពី ១០០នាក់ ទៅ ១៥០នាក់ ក្នុងមួយខែ ដោយនិយោជកត្រូវចំណាយប្រាក់កាដូរៀបអាពាហ៍ពិពាហ៍ចន្លោះពីចំនួន ១០០០ ដុល្លារអាមេរិក ទៅ ១ ៥០០ ដុល្លារអាមេរិក ក្នុងមួយខែ។ ដូចនេះ និយោជកមិនមានលទ្ធភាពផ្តល់ប្រាក់កាដូរៀបអាពាហ៍ពិពាហ៍ ជូនកម្មករនិយោជិតបន្តទៀតទេ។

## ហេតុផលនៃសេចក្តីសម្រេច ៖

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកផ្តល់ប្រាក់ចំនួន ១០ដុល្លារអាមេរិក សម្រាប់ឆ្នាំដែលកម្មករនិយោជិតដែលសុំច្បាប់ពិសេសរៀបអាពាហ៍ពិពាហ៍ ដូចពីមុន**

យោងតាមអង្គហេតុ ភាគីកម្មករនិយោជិតបានអះអាងថា ចាប់ពី២០១៩ រហូតដល់បច្ចុប្បន្ន (ថ្ងៃសវនាការ) មិនមានកម្មករនិយោជិតណាម្នាក់ដែលជាសមាជិកសហជីពកម្ពុជាឯករាជ្យ បានរៀបអាពាហ៍ពិពាហ៍ទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាដូចខាងក្រោម ៖

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ១៨១/១៤-ស្បុង យិន (ខេមបូឌា) ប៊ី ប៊ិកស្តាយ៍ ហេតុផលនៃចំណុចវិវាទទី១ បានបកស្រាយថា ៖ *"...ដោយហេតុថា គ្មានភាគីវិវាទ ឬដើមបណ្តឹងដាក់លាក់ និងគ្មានភស្តុតាងដើម្បីគាំទ្រអំណះអំណាង ដែលថាកម្មករនិយោជិតផ្នែកឆែក និងផ្នែកប៉ះ ទទួលបានប្រាក់ឈ្នួលក្រោមប្រាក់ឈ្នួលអប្បរមា ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចសម្រេចទៅលើអង្គសេចក្តីនៃចំណុចវិវាទនេះបានទេ។ សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ...។" (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ២៣០/១៦-វ៉ា ឡុង (ខេមបូឌា) អៅស៊ូល អ៊ិនដាស្ទ្រី ហេតុផលនៃចំណុចវិវាទទី៥ និងលេខ ០២៦/១៩-ណា ផុង ហ្គាម៉ិន ឯ.ក ហេតុផលនៃចំណុចវិវាទទី១៤)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

តាមរយៈការអះអាងរបស់ភាគីកម្មករនិយោជិតខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្នុងចំណោមភាគីកម្មករនិយោជិតដែលជាដើមបណ្តឹងចំនួន ១៣នាក់ មិនមានកម្មករនិយោជិតណាម្នាក់បានរៀបអាពាហ៍ពិពាហ៍នោះទេ។

នៅក្នុងសវនាការ កម្មករនិយោជិតបានស្នើសុំដាក់ឯកសារបញ្ជាក់នូវចំនួនកម្មករនិយោជិត ដែលបានរៀបអាពាហ៍ពិពាហ៍ ហើយមិនបានទទួលប្រាក់កាដូរៀបអាពាហ៍ពិពាហ៍។ ដោយឡែក នៅថ្ងៃផុតកំណត់ដាក់ឯកសារ ភាគីកម្មករនិយោជិតមិនបានដាក់ឯកសារសារណាបញ្ជាក់ ឬ ភស្តុតាងណាមួយដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីពិចារណាឡើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទារនេះ គឺមិនមានដើមបណ្តឹងដាក់លាក់ជាកម្មករនិយោជិតដែលបានរៀបអាពាហ៍ពិពាហ៍ មកធ្វើការទាមទារនោះទេ។

យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ចំនួន ១០ដុល្លារអាមេរិក សម្រាប់ចងដៃកម្មករនិយោជិតដែលសុំច្បាប់ពិសេសរៀបអាពាហ៍ពិពាហ៍ ដូចពីមុនៗ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទ ៖**

- បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ចំនួន ១០ដុល្លារអាមេរិក សម្រាប់ចងដៃកម្មករនិយោជិតដែលសុំច្បាប់ពិសេសរៀបអាពាហ៍ពិពាហ៍ ដូចពីមុនៗ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ឹម សុទ្ធី**

ហត្ថលេខា ៖ ------------

THE ARBITRATION COUNCIL

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖
ឈ្មោះ ៖ **អន ណាន**
ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖
ឈ្មោះ ៖ **អាំង អេងថុង**
ហត្ថលេខា ៖ ------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL